# ការបង្ហាញព័ត៌មានទាន់ពេល

ឈ្មោះក្រុមហ៊ុនចុះបញ្ជី : កំពង់ផែស្វយ័តក្រុងព្រះសីហនុ

លេខកូដក្រុមហ៊ុនចុះបញ្ជី : KH1000060009

កាលបរិច្ឆេទនិងពេលវេលានៃការបញ្ជូន : **ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៦ ម៉ោង១៥:៣០នាទី**

## ហេតុការណ៍ពាក់ព័ន្ធនឹងការគ្រប់គ្រង ( ទម្រង់ គ.១ )

| សេចក្តីសម្រេចកោះប្រជុំមហាសន្និបាតភាគហ៊ុនិក | |
|---|---|
| ១. ប្រភេទ នៃការប្រជុំភាគហ៊ុនិក | ប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញ |
| ២. កាលបរិច្ឆេទ និងពេលវេលាប្រជុំ | ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៦, ម៉ោង៧:០០នាទី |
| ៣. ទីកន្លែងប្រជុំ | សណ្ឋាគារ សុខា ប៊ិច រីស៊ត, ខេត្តព្រះសីហនុ |
| ៤. របៀបវារៈ | • ការចុះវត្តមាន ភាគហ៊ុនិកចូលរួម<br>• ប្រកាសហេតុ និងគោរពភ្លេងជាតិ<br>• មតិស្វាគមន៍របស់ប្រធានមហាសន្និបាតភាគហ៊ុនិក<br>• មតិ **ឯកឧត្តម ប៉េង ពោធិ៍នា** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន<br>• មតិចូលរួមរបស់ភាគហ៊ុនិកជប៉ុន<br>• បទបង្ហាញស្តីពី៖<br>ក. របាយការណ៍ លទ្ធផលការងារអាជីវកម្ម-សេវាកម្ម ឆ្នាំ២០២៥ និង ទិសដៅការងារឆ្នាំ២០២៦<br>ខ. នីតិវិធី សម្រាប់ការបោះឆ្នោតបែងចែកភាគលាភជូនភាគហ៊ុនិក ឆ្នាំ២០២៥, ប្រាក់លាភការក្រុមប្រឹក្សាភិបាល និងមន្ត្រីត្រួតពិនិត្យរដ្ឋអម កសស សម្រាប់ឆ្នាំ២០២៦<br>គ. សំណួរ-ចម្លើយ<br>• ដំណើរការបោះឆ្នោត<br>• ប្រកាសលទ្ធផល និងមតិបិទកម្មវិធី |
| ៥. កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះ ភាគហ៊ុនិកដែលអាចចូលរួម | ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៦ |
| ៦. កាលបរិច្ឆេទ នៃសេចក្តីសម្រេច | ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៦ |
| ៧. ផ្សេងៗ | |

- ឯកសារភ្ជាប់ ៖ សេចក្តីជូនដំណឹង ស្តីពីកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក លើកទី៩ របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ។

**ហត្ថលេខា និងឈ្មោះបុគ្គលិក**
**ទទួលបន្ទុកក្នុងការផ្តល់ព័ត៌មាន**

**ពិត ច្រាកដ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ

លេខៈ ០១៥ សជណ/កសស/បេ.ធម

ថ្ងៃ ចន្ទ ១០កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ខេត្តព្រះសីហនុ ថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០២៦

# សេចក្តីជូនដំណឹង
## ស្តីពី
## កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក លើកទី៩ របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស)** មានកិត្តិយសសូមគោរពជម្រាបជូនដំណឹងដល់ភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ "ខ" និងប្រភេទ "គ" ទាំងអស់មេត្តាជ្រាបថា ៖ អនុលោមតាម ស្មារតីអង្គប្រជុំក្រុមប្រឹក្សាភិបាល ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៦, **កសស** នឹងរៀបចំការប្រជុំមហាសន្និបាតភាគហ៊ុនិក លើកទី៩ ទៅតាមកាលបរិច្ឆេទកំណត់ ដូចខាងក្រោម ៖

១. ប្រភេទនៃការប្រជុំភាគហ៊ុនិក ៖ **មហាសន្និបាតភាគហ៊ុនិកសាមញ្ញ**
២. កាលបរិច្ឆេទកំណត់ទុក (Record Date) ៖ **ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៦**
៣. កាលបរិច្ឆេទអិចរាយថ៍ (Ex-rights) ៖ **ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៦**
៤. កាលបរិច្ឆេទ មហាសន្និបាតភាគហ៊ុនិក ៖ **ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៦**
៥. ទីកន្លែងប្រារព្ធពិធី មហាសន្និបាតភាគហ៊ុនិក ៖ **សណ្ឋាគារ សុខា បិច រីសត, ខេត្តព្រះសីហនុ**
៦. របៀបវារៈ នៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក មានដូចខាងក្រោម ៖

- ការចុះវត្តមាន ភាគហ៊ុនិកចូលរួម
- ប្រកាសហេតុ និងគោរពភ្លេងជាតិ
- មតិស្វាគមន៍របស់ប្រធានមហាសន្និបាតភាគហ៊ុនិក
- មតិ **ឯកឧត្តម ប៉េង ពោធិ៍នា** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន
- មតិចូលរួមរបស់ភាគហ៊ុនិកជប៉ុន
- បទបង្ហាញស្តីពី ៖
  ក. របាយការណ៍ លទ្ធផលការងារអាជីវកម្ម-សេវាកម្ម ឆ្នាំ២០២៥ និងទិសដៅការងារ ឆ្នាំ២០២៦
  ខ. នីតិវិធីសម្រាប់ការបោះឆ្នោតបែងចែកភាគលាភជូនភាគហ៊ុនិក ឆ្នាំ២០២៥, ប្រាក់លាភការក្រុមប្រឹក្សាភិបាល និងមន្ត្រីត្រួតពិនិត្យរដ្ឋអម កសស សម្រាប់ឆ្នាំ២០២៦
  គ. សំណួរ-ចម្លើយ
- ដំណើរការបោះឆ្នោត
- ប្រកាសលទ្ធផល និង មតិបិទកម្មវិធី

**បញ្ជាក់ ៖**

ភាគហ៊ុនិកដែលមានសិទ្ធិចូលរួមកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក ដូចបានកំណត់ខាងលើនេះ ជាភាគហ៊ុនិកដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះផ្លូវការ ដោយទទួលបានពីបញ្ជីឈ្មោះភាគហ៊ុនិកដែលរៀបចំឡើងនា **ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៦** ។



តិរវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
Tarak Vithei Samdech Akka Moha Sena Padei Techo HUN SEN
Sangkat Nº 3, Preah Sihanouk City, Preah Sihanouk Province
Office : 034 933 416; 034 933 511 Pilot : 034 933 507; Fax: 034 933 693
E-mail: pasinfo@pas.gov.kh;spsez@pas.gov.kh
Website: www.pas.gov.kh

ភាគហ៊ុនិកដែលមានឈ្មោះ ក្នុងបញ្ជីឈ្មោះភាគហ៊ុនិកនៅកាលបរិច្ឆេទកំណត់ទុក **ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៦** នឹងទទួលបានលិខិតអញ្ជើញ តាមរយៈមធ្យោបាយអេឡិចត្រូនិកពី ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ នៃធនាគារ អេស៊ីលីដា ភីអិលស៊ី ឬអាចស្នើសុំមក **កសស** តាមរយៈលេខទូរស័ព្ទទំនាក់ទំនង ដូចមានភ្ជាប់មកជាមួយ **ចាប់ពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៦ ដល់ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៦** ។

ភាគហ៊ុនិកដែលធ្វើការលក់មូលបត្រកម្មសិទ្ធិរបស់ខ្លួននាថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៦ នៅតែមានសិទ្ធិចូលរួម និងបោះឆ្នោតក្នុងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកតាមកាលកំណត់ខាងលើ ។

ភាគហ៊ុនិកដែលធ្វើការទិញមូលបត្រកម្មសិទ្ធិរបស់ខ្លួននាថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៦ មិនមានសិទ្ធិចូលរួម និងបោះឆ្នោតក្នុងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកតាមកាលកំណត់ខាងលើនោះទេ ។

បន្ទាប់ពីទទួលបានលិខិតអញ្ជើញតាមរយៈការជូនដំណឹងខាងលើ ភាគហ៊ុនិកដែលមានបំណងចូលរួម ឬ ចាត់តំណាងចូលរួម (ភ្ជាប់ជាមួយនឹងទម្រង់ "លិខិតតែងតាំងអាណត្តិគាហកៈ") ក្នុងកិច្ចប្រជុំមហាសន្និបាត សូមបញ្ជាក់ការចូលរួមជាមួយ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ នៃធនាគារ អេស៊ីលីដា ភីអិលស៊ី ឬ កសស យ៉ាងយូរត្រឹម **ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០២៦** ទៅតាមអាសយដ្ឋាន និងព័ត៌មានទំនាក់ទំនង ដូចខាងក្រោម ៖

**១. កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស)**

- អាសយដ្ឋាន: តិរវិថីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន, សង្កាត់លេខ ៣, ក្រុង-ខេត្តព្រះសីហនុ
- ទូរស័ព្ទ ឬ ប្រព័ន្ធតេឡេក្រាម: (៨៥៥) ១០ ៧៨៨ ៨៨០ / ១០ ៥០៧ ៨៨៨ / ៩៥ ៦៦៨ ៨៩៧
- សារអេឡិចត្រូនិច: pasinfo@pas.gov.kh

**២. ធនាគារ អេស៊ីលីដា ភីអិលស៊ី**

- អាសយដ្ឋាន: អគារលេខ ៦១, មហាវិថីព្រះមុនីវង្ស, សង្កាត់ស្រះចក, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ
- **លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ**
  ទូរស័ព្ទ: (៨៥៥) ៧០ ៥០០ ៣៧៧
  អ៊ីម៉ែល: samreth.vannybopharath@acledabank.com.kh
- **លោក កែន រិទ្ធពុទ្ធា**
  ទូរស័ព្ទ: (៨៥៥) ១៥ ៨០០ ៦៦៣
  អ៊ីម៉ែល: ken.rithputhea@acledabank.com.kh
- **កញ្ញា ចាន់ ទេពកញ្ញា**
  ទូរស័ព្ទ: (៨៥៥) ១៦ ២៩៥ ៤៣២
  អ៊ីម៉ែល: op.rtp@acledabank.com.kh

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជាប្រធានអគ្គនាយក**

PORT AUTONOME DE SIHANOUKVILLE

**លូ គឹមឈន់**

**ចម្លងជូន៖**

- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- និយ័តករមូលបត្រកម្ពុជា
- ក្រុមប្រឹក្សាភិបាល កសស
- មន្ត្រីត្រួតពិនិត្យផ្ទៃក្នុង កសស
  "ដើម្បីជូនជ្រាប"
- ផ្សារមូលបត្រកម្ពុជា និង ក្រុមហ៊ុនមូលបត្រ
  "ដើម្បីជូនផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ



តិរវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
Tarak Vithei Samdech Akka Moha Sena Padei Techo HUN SEN
Sangkat Nº 3, Preah Sihanouk City, Preah Sihanouk Province
Office : 034 933 416; 034 933 511 Pilot : 034 933 507; Fax: 034 933 693
E-mail: pasinfo@pas.gov.kh;spsez@pas.gov.kh
Website: www.pas.gov.kh